**ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងពិធីបង្ហាញម៉ូដែលរថយន្ត Ghost Series II ក្នុងអគារតាំងបង្ហាញ របស់ក្រុមហ៊ុន Rolls-Royce Motor Cars Phnom Penh**





នៅព្រឹកថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៥ ក្រុមហ៊ុន **Rolls-Royce Motor Cars Phnom Penh** បានបើកសម្ពោធអគារតាំងបង្ហាញរថយន្តដ៏ថ្មីសន្លាងរបស់ខ្លួន នៅក្នុងរាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅអគារលេខ ៣៧-៣៨ ផ្លូវ២១៧ សង្កាត់វាលវង់ ខណ្ឌ៧ មករា ដោយតាំងបង្ហាញនូវរថយន្តម៉ូដែលមហាប្រណីត **Ghost Series II** ជូនភ្ញៀវចូលរួម និងអតិថិជន ក្រោមអធិបតីភាពឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

លោក **Temmy Wiradjaja** នាយកចាត់ការទូទៅរបស់ក្រុមហ៊ុន **Rolls-Royce Motor Cars Phnom Penh** បានថ្លែងថា **:** យើងមានមោទនភាព ចំពោះការបើសម្ពោធអាគារតាំងបង្ហាញរថយន្តថ្មី និងអគារផ្តល់សេវាថែទាំរថយន្តរបស់ក្រុមហ៊ុនផងដែរ ។ ដូច្នេះយើងនឹងអាចផ្តល់ជូនអតិថិជនរបស់យើងនូវបទពិសោធន៍ពេញលេញ ក្នុងការបញ្ជាកុម្ម៉ង់រថយន្ត Rolls-Royce ក៏ដូចជា បានទទួលរាល់សេវាថែទាំ នៅពេលដែលពួកគាត់ក្លាយជាម្ចាស់លើរថយន្ត Rolls-Royce ដ៏ទំនើបនេះ ។

លោកប្រធានបានបន្ថែមថា**:**ការបើកសម្ពោធនូវអគារតាំងបង្ហាញនេះ ធ្វើឡើងបន្ទាប់ពីក្រុមហ៊ុន HGB Group Co,Ltd ត្រូវបានតែងតាំងជាភ្នាក់ងារចែកចាយផ្លូវការសម្រាប់រថយន្ត Rolls-Royce ប្រចាំទីក្រុងភ្នំពេញ កាលពីខែមិថុនា ឆ្នាំ២០១៤ ។ អគារតាំងបង្ហាញនេះ មានផ្ទៃក្រឡា ៥៤០ ម៉ែត្រការ៉េ ដែលអាចតាំងបង្ហាញរថយន្ត បាន ០៤ គ្រឿង ។ ដូច្នេះអគារតាំងបង្ហាញនេះ ជាអគារតាំងបង្ហាញរថយន្តមហាទំនើបធំជាងគេ ក្នុងប្រវត្តិសាស្ត្រក្រុងភ្នំពេញ ។



លោក **Paul Harris** នាយកក្រុមហ៊ុន **Rolls-Royce Motor Cars** ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក បានថ្លែងថា**:** អតិថិជនយើងជាច្រើនគឺជាសហគ្រិន ដែលជោគជ័យ និងជាថ្នាក់ដឹកនាំក្នុងវិស័យនានា ដែលជួយចូលរួមចំណែកដល់វិស័យសេដ្ឋកិច្ចជាតិ ។ រថយន្ត **Rolls Royce** ម៉ូដែល **Ghost Series II** គឺជាប្រភេទរថយន្តដែលស្របនិងការចង់បានរបស់ពួកគាត់ ដែលអាចផ្តល់នូវកន្លែងស្ងប់សុខ នៅក្នុងពិភពជំនួញដ៏មមាញឹក ។ នៅពេលនេះ ពួកគាត់ក៏អាចរីករាយក្នុងការបញ្ជាកុម្ម៉ង់រថយន្ត Rolls Royce តាមរយៈកម្មវិធីច្នៃកុម្ម៉ង់ (Bespoke) ផងដែរ ។




មានប្រសាសន៍នាឱកាសនោះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួង និងឯកឧត្តមផ្ទាល់ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងទឹកចិត្តរីករាយ និងអបអរសាទរចំពោះពិធី បើកសម្ពោធអគារតាំងបង្ហាញរថយន្តដ៏ថ្មីសន្លាងរបស់ក្រុមហ៊ុន **Rolls-Royce Motor Cars** ក្នុងរាជធានីភ្នំពេញ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា:ការគិត និងការសម្រេចចិត្តរបស់ក្រុមហ៊ុន ក្នុងការនាំចូលរថយន្តម៉ូដែលមហាប្រណីតមកកាន់ព្រះរាជាណាចក្រកម្ពុជា គឺពិតជាត្រឹមត្រូវស្របពេលដែលកម្ពុជា ជាប្រទេសប្រកាន់របបទីផ្សារសេរី ប្រជាពលរដ្ឋដែលមានជីវភាពចាប់ពីថ្នាក់កណ្តាលទៅអាច មានលទ្ធភាពទិញរថយន្តប្រភេទនេះប្រើប្រាស់ ពីព្រោះជាប្រភេទរថយន្ត ដែលមានលក្ខណៈល្អប្រណីត ដែលអាចចាត់ទុកថា:ជាប្រភេទរថយន្តអល័ង្ការ សមស្របសម្រាប់មនុស្សជំនាន់ថ្មី ដែលមានជោគជ័យក្នុងរបរជំនួញ និងការងារក្នុងវិស័យនានារបស់ពួកគេ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានធ្វើការកោតសរសើរចំពោះ ក្រុមហ៊ុន **HGB Group Co,Ltd** ដែលបាននាំមុខគេក្នុងការចាប់ដៃគូជាមួយក្រុមហ៊ុនក្រៅស្រុក ក្នុងការនាំចូលម៉ាកផលិតផលល្បីៗលើពិភពលោកមកធ្វើការចែកចាយនៅទីផ្សារកម្ពុជា ដូចជា: **Vertu ,Zumex, Victorinox,CK,Samsonite,American tourister, Desley, Nikon** ។ រីឯ ប្រភេទរថយន្ត មានដូចជា ម៉ាក **KIA** និង **Mazda** ជាដើម ។ ជាពិសេសនៅពេលខាងមុខ ក្រុមហ៊ុននឹងសម្រេចចិត្តនាំចូលនូវប្រភេទម៉ូតូ ម៉ាក **KAWASAKI** មកទីផ្សារកម្ពុជាផងដែរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានជូនពរ និងសង្ឃឹមថា:ក្រុមហ៊ុន នឹងទទួលបានជោគជ័យ ក្នុងអាជីវកម្មរបស់ខ្លួនជាបន្តបន្ទាប់ទៀត ។



បន្ទាប់មក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ និងថ្នាក់ដឹកនាំ ក្រុមហ៊ុន បានអញ្ជើញកាត់ខ្សែបូរសម្ពោធអគារតាំងបង្ហាញរថយន្ត **Rolls-Royce** អញ្ជើញពិនិត្យ មើលភាពប្រណីតនៃរថយន្តម៉ូដែល **Ghost Series II** ផងដែរ ។







